BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិក្នុងសំណុំរឿងអំពើហិង្សាក្នុងគ្រួសារ



ឆ្នាំ ២០២៥.

តើជំនួយគតិយុត្តិជាអ្វី?

ជំនួយគតិយុត្តិ គឺជាការផ្តល់សេវាគតិយុត្តិដោយឥតគិតថ្លៃ ជូនអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងរឿងក្តីជំនួយគតិយុត្តិ ស្រប តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជំនួយគតិយុត្តិ។

អ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិ រួមមាន៖

- អ្នកមានគុណបំណាច់ចំពោះបដិវត្តន៍។
- អ្នកស្ថិតក្នុងគ្រួសារក្រីក្រ។
- កុមារ។
- ជនជាតិភាគតិចដែលរស់នៅតំបន់មានលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមលំបាកជាពិសេស។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ៖ គឺជាអ្នកត្រូវបានចោទប្រកាន់ អ្នកត្រូវបានស្នើសុំឲ្យចោទប្រកាន់ អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកជាប់ចោទ ជនរងគ្រោះ សាក្សី អ្នកអនុវត្តវិធានការដោះស្រាយបែបបង្វែរទិស និងទណ្ឌិត (អនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០២៦)។
- អ្នកចុងចោទដែលស្ថិតក្នុងគ្រួសារបៀតក្រីក្រ។
- ជនរងគ្រោះ អ្នកកំពុងស្ថិតក្នុងដំណើរការបញ្ជាក់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកអាយុក្រោម ១៨ ឆ្នាំដែលទៅជាមួយ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្ស។
- អ្នកស្ថិតក្នុងករណីណាមួយដូចខាងក្រោម ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ៖
- ឪពុកបង្កើត ម្តាយបង្កើត ភរិយា ស្វាមី កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ចិញ្ចឹមបីបាច់យុទ្ធជនពលីកាលនៅតូច។
- អ្នកឆ្លងជាតិពុលពណ៌ទឹកក្រូច (ដាយអុកស៊ីន)។
- មនុស្សចាស់។
- ជនពិការ។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលជាជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ។
- ជនរងគ្រោះក្នុងរឿងក្តីអំពើហិង្សាក្នុងគ្រួសារ។
- អ្នកផ្ទុកមេរោគអេដស៍ (HIV)។

មុខសញ្ញាដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិដោយឥតគិតថ្លៃ នៅពេលមានបញ្ហាជាប់ពាក់ព័ន្ធនឹងច្បាប់ សូមអញ្ជើញមកកាន់មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋនៅមូលដ្ឋាន ដើម្បីទទួលបានជំនួយដោយឥតគិតថ្លៃទាំងស្រុង។

អាសយដ្ឋានទំនាក់ទំនងដើម្បីស្នើសុំជំនួយគតិយុត្តិ៖

- មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌ខេត្ត និងក្រុងក្រោមឱវាទថ្នាក់កណ្តាល។
- អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលចូលរួមជំនួយគតិយុត្តិ។
- អាសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅ៖
- គេហទំព័រនីតិកម្មជាតិ *(https://phapluat.gov.vn/)*
- គេហទំព័រព័ត៌មានអេឡិចត្រូនិកក្រសួងយុត្តិធម៌ *(https://dstrogiupphaply.moj.gov.vn/all/searchOrganization)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកជំនួយគតិយុត្តិវៀតណាម *(https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកមន្ទីរយុត្តិធម៌។
- លោកអ្នកអាចទាក់ទងតាមបណ្តាញដូចខាងក្រោម ដើម្បីដឹងព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖
- ខ្សែទូរស័ព្ទទាន់ហេតុការណ៍អំពីជំនួយគតិយុត្តិ៖ *18001233/02462739631*
- ទាញយកកម្មវិធីទូរស័ព្ទចល័តអំពីជំនួយគតិយុត្តិ។

តើអំពើហិង្សាក្នុងគ្រួសារជាអ្វី?

អំពើហិង្សាក្នុងគ្រួសារ គឺជាទង្វើដោយចេតនារបស់សមាជិកគ្រួសារ ដែលបង្កគ្រោះថ្នាក់ ឬអាចបង្កគ្រោះថ្នាក់ខាងរាងកាយ ស្មារតី ផ្លូវភេទ និងសេដ្ឋកិច្ច ចំពោះសមាជិកដទៃទៀតក្នុងគ្រួសារ (តាមមាត្រា ២ នៃច្បាប់ស្តីពីការទប់ស្កាត់ និងប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ២០២២)។

ទង្វើអំពើហិង្សាក្នុងគ្រួសារ (មាត្រា ៣ នៃច្បាប់ស្តីពីការទប់ស្កាត់ និងប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ២០២២)

- ធ្វើទុក្ខបុកម្នេញ ធ្វើបាប វាយដំ គំរាមកំហែង ឬទង្វើដោយចេតនាផ្សេងទៀត ដែលបំពានដល់សុខភាព និងអាយុជីវិត។
- ជេរប្រមាថ ថ្នាំងថ្នាក់ ឬទង្វើដោយចេតនាផ្សេងទៀត ដែលប្រមាថដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរ។
- បង្ខិតបង្ខំឲ្យមើលឃើញអំពើហិង្សាចំពោះមនុស្ស ឬសត្វ ក្នុងគោលបំណងបង្កសម្ពាធផ្លូវចិត្តជាប្រចាំ។
- បោះបង់ចោល មិនយកចិត្តទុកដាក់ មិនចិញ្ចឹមបីបាច់ ថែរក្សាសមាជិកគ្រួសារដែលជាកុមារ ស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងចិញ្ចឹមកូនអាយុក្រោម ៣៦ ខែ មនុស្សចាស់ ជនពិការ អ្នកគ្មានលទ្ធភាពថែរក្សាខ្លួនឯង។ មិនអប់រំសមាជិកគ្រួសារដែលជាកុមារ។
- រើសអើង ប្រកាន់បែងចែកអំពីរូបរាង យេនឌ័រ ភេទ និងសមត្ថភាពរបស់សមាជិកគ្រួសារ។
- រារាំងសមាជិកគ្រួសារមិនឲ្យជួបជុំសាច់ញាតិ មិនឲ្យមានទំនាក់ទំនងសង្គមស្របច្បាប់ និងមានសុខមាលភាព ឬទង្វើផ្សេងទៀត ក្នុងគោលបំណងញែកដាច់ បង្កសម្ពាធផ្លូវចិត្តជាប្រចាំ។
- រារាំងការអនុវត្តសិទ្ធិ និងករណីយកិច្ចក្នុងទំនាក់ទំនងគ្រួសាររវាងជីដូនជីតា និងចៅ រវាងឪពុកម្តាយ និងកូន រវាងប្តី និងប្រពន្ធ រវាងបងប្អូននឹងគ្នា។
- លាតត្រដាង ឬផ្សព្វផ្សាយព័ត៌មានអំពីជីវិតឯកជន អាថ៌កំបាំងផ្ទាល់ខ្លួន និងអាថ៌កំបាំងគ្រួសាររបស់សមាជិកគ្រួសារ ក្នុងគោលបំណងប្រមាថដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរ។
- បង្ខិតបង្ខំឲ្យរួមភេទផ្ទុយនឹងឆន្ទៈរបស់ភរិយា ឬស្វាមី។
- បង្ខិតបង្ខំឲ្យសម្តែងទង្វើអាសអាភាស បង្ខិតបង្ខំឲ្យស្តាប់សំឡេង មើលរូបភាព អានខ្លឹមសារអាសអាភាស ដែលជំរុញឲ្យមានអំពើហិង្សា។
- បង្ខិតបង្ខំឲ្យរៀបការមុនអាយុ រៀបការ លែងលះ ឬរារាំងការរៀបការ លែងលះស្របច្បាប់។
- បង្ខិតបង្ខំឲ្យមានផ្ទៃពោះ រំលូតកូន ជ្រើសរើសភេទទារកក្នុងផ្ទៃ។
- ត្រួតត្រាយកបាន បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរួមរបស់គ្រួសារ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សមាជិកដទៃទៀតក្នុងគ្រួសារ។
- បង្ខិតបង្ខំសមាជិកគ្រួសារឲ្យសិក្សា ធ្វើការហួសកម្លាំង រួមចំណែកហិរញ្ញវត្ថុហួសពីលទ្ធភាពរបស់ខ្លួន គ្រប់គ្រងទ្រព្យសម្បត្តិ ចំណូលរបស់សមាជិកគ្រួសារក្នុងគោលបំណងបង្កឲ្យមានស្ថានភាពពឹងផ្អែកខាងសម្ភារៈ ស្មារតី ឬផ្នែកផ្សេងទៀត។
- ញែកដាច់ ឃុំឃាំងសមាជិកគ្រួសារ។
- បង្ខិតបង្ខំសមាជិកគ្រួសារឲ្យចេញពីទីលំនៅស្របច្បាប់ ដោយផ្ទុយច្បាប់។

ទម្រង់ជំនួយគតិយុត្តិសម្រាប់អ្នករងអំពើហិង្សាក្នុងគ្រួសារ៖



- ការប្រឹក្សាច្បាប់



- ការចូលរួមក្នុងនីតិវិធី



- ការតំណាងក្រៅនីតិវិធី

សំណុំឯកសារស្នើសុំជំនួយគតិយុត្តិ រួមមាន៖

- ពាក្យស្នើសុំជំនួយគតិយុត្តិ *(តាមទម្រង់លេខ 02-TP-TGPL ដែលចេញផ្សាយភ្ជាប់ជាមួយសារាចរណែនាំលេខ 12/2018/TT-BTP)*។
- លិខិតស្នាម និងឯកសារនានាដែលពាក់ព័ន្ធនឹងរឿងក្តីជំនួយគតិយុត្តិ។
- លិខិតស្នាមបញ្ជាក់ថាជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ។
  - សេចក្តីសម្រេចទទួលយកជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារចូលទៅក្នុងផ្ទះសង្គម ឬមូលដ្ឋានឧបត្ថម្ភសង្គម។
  - លិខិតបញ្ជាក់គ្រួសារក្រីក្រ ភ្ជាប់ជាមួយលិខិតស្នាមមួយក្នុងចំណោមប្រភេទដូចខាងក្រោម៖ លិខិតបញ្ជាក់របស់មូលដ្ឋានពិនិត្យ និងព្យាបាលជំងឺ អំពីការពិនិត្យ និងព្យាបាលរបួសដែលបង្កឡើងដោយទង្វើអំពើហិង្សាក្នុងគ្រួសារ។ សេចក្តីសម្រេចហាមឃាត់អ្នកបង្កអំពើហិង្សាក្នុងគ្រួសារមិនឲ្យទាក់ទងជាមួយជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។ សេចក្តីសម្រេចដោះស្រាយការបំពានរដ្ឋបាលចំពោះអ្នកមានទង្វើអំពើហិង្សាក្នុងគ្រួសារ។

សំណុំឯកសារស្នើសុំជំនួយគតិយុត្តិ អាចដាក់ស្នើតាមមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយទាំង ៣ ដូចខាងក្រោម៖

- ដាក់ស្នើដោយផ្ទាល់
- ផ្ញើតាមរយៈសេវាប្រៃសណីយ៍
- ផ្ញើតាមរយៈហ្វាក់ស៍ ឬទម្រង់អេឡិចត្រូនិក

របៀបផ្ញើសំណុំឯកសារស្នើសុំជំនួយគតិយុត្តិ

- ទម្រង់ដោយផ្ទាល់៖

(១) មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌នៅមូលដ្ឋាន។

(២) សាខារបស់មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ។

(៣) អង្គការដែលបានចុះឈ្មោះចូលរួមជំនួយគតិយុត្តិ រួមមានអង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលបានចុះឈ្មោះចូលរួមជំនួយគតិយុត្តិជាមួយមន្ទីរយុត្តិធម៌នៅមូលដ្ឋាន។

(៤) អង្គការដែលបានចុះកិច្ចសន្យាអនុវត្តជំនួយគតិយុត្តិ រួមមានអង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលបានចុះកិច្ចសន្យាអនុវត្តជំនួយគតិយុត្តិជាមួយមន្ទីរយុត្តិធម៌។

- ទម្រង់អនឡាញ៖

- ចូលទៅកាន់គេហទំព័រសេវាសាធារណៈជាតិ នៅកន្លែងដែលអ្នករស់នៅ។
- ស្វែងរក និងជ្រើសរើសនីតិវិធី “ស្នើសុំជំនួយគតិយុត្តិ”។
- បំពេញព័ត៌មានឲ្យបានគ្រប់គ្រាន់ក្នុងពាក្យស្នើសុំ ចំណុចដែលមានសញ្ញាផ្កាយ (*) គឺជាកាតព្វកិច្ចត្រូវបំពេញ។
- បញ្ចប់ដំណើរការដោយដាក់ស្នើសំណុំឯកសារ តាមការណែនាំនៅលើគេហទំព័រ។

